**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែតម្រូវឡើងវិញមាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃ អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពល-ខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និង ពិការ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** មាត្រា ៣ មាត្រា ៦ និង មាត្រា ៧ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និង ពិការ ត្រូវបានកែតម្រូវឡើងវិញដូចតទៅ :

មាត្រា៣ថ្មី : ការវាយតម្លៃប្រភេទថ្នាក់ពិការ គឺត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយ របស់ក្រសួងការពារជាតិ ដោយផ្អែកតាមប្រកាសអន្តរក្រសួង ដែលមានសមាសភាព :

- ក្រសួងការពារជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

មាត្រា៦ថ្មី : យោធិនទាំងពីរភេទ ដូចមានចែងក្នុងមាត្រា ២ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ :

ក- ចំពោះយោធិនពិការប្រភេទ "ក" គ្រប់កំរិតថ្នាក់ :

១- ក្រោយពេលព្យាបាលជម្ងឺរបួស ជាសះស្បើយ និងមានលំនឹង ត្រូវបានទទួលរបបឧបត្ថម្ភបំប៉នសុខភាពនៅមជ្ឈមណ្ឌលបំប៉នសុខភាព តាមរយៈពេលកំណត់ និងតាមកំរិតថ្នាក់ពិការ គឺ :

- កំរិតថ្នាក់ ១ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនកៅសិប (៩០) ថ្ងៃ
- កំរិតថ្នាក់ ២ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនហុកសិប (៦០) ថ្ងៃ
- កំរិតថ្នាក់ ៣ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនសែសិបប្រាំ (៤៥) ថ្ងៃ
- កំរិតថ្នាក់ ៤ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនសាមសិប (៣០) ថ្ងៃ

២- យោធិនពិការ ប្រសិនបើនៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ បានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃបៀវត្ស សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមកំរិតថ្នាក់ពិការ គឺបន្ថែមលើប្រាក់បៀវត្សប្រចាំខែផ្ទាល់ខ្លួន ។

- កំរិតថ្នាក់ ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសែសិបប្រាំ (៤៥) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសែសិប (៤០) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៣ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសាមសិបប្រាំ (៣៥) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសាមសិប (៣០) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

៣- យោធិនពិការ ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបំរើការងារមិនលើសពីម្ភៃបួន (២៤) ខែ ដោយគិតរយៈពេលបំរើកងយោធពលខេមរភូមិន្ទ ក្នុងមួយ (១) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួនពីរ (២) ខែ ។ ចំពោះយោធិនពិការដែលបំរើកងទ័ពមិនទាន់គ្រប់រយៈពេលមួយ (១) ឆ្នាំ ហើយត្រូវពិការក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួនពីរ (២) ខែដែរ ។

៤- យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូង ស្មើនឹងទឹកប្រាក់ចំនួន :

- កំរិតថ្នាក់ ១ ទទួលទឹកប្រាក់សរុបចំនួនដប់ពីរ (១២) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ២ ទទួលទឹកប្រាក់សរុបចំនួនដប់ (១០) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៣ ទទួលទឹកប្រាក់សរុបចំនួនប្រាំបី (០៨) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៤ ទទួលទឹកប្រាក់សរុបចំនួនប្រាំមួយ (០៦) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

៥- បានបន្តទទួលបើកប្រាក់បៀវត្សសរុបប្រចាំខែ ហើយបៀវត្សសរុបនោះត្រូវគិតតាមឋានន្តរសក្តិចុងក្រោយ មុនពេលសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ និងចំនួនកូននៅក្នុងបន្ទុកជាក់ស្តែងរបស់យោធិនពិការ ។

៦- យោធិនពិការដែលរស់នៅក្នុងមណ្ឌល យោធិនដែលចេញពីជួរកងយោធពលខេមរ-ភូមិន្ទ ត្រូវបានទទួលបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែ ដោយគិតជាសមាមាត្រលើប្រាក់បៀវត្សសរុបប្រចាំខែ ដូចខាងក្រោម :

- កំរិតថ្នាក់ ១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងមួយរយ (១០០) ភាគរយ

- កំរិតថ្នាក់ ២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងប៉ែតសិប (៨០) ភាគរយ

- កំរិតថ្នាក់ ៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងហុកសិប (៦០) ភាគរយ

- កំរិតថ្នាក់ ៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងសែសិប (៤០) ភាគរយ

៧-យោធិនពិការកំរិតថ្នាក់ ១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបំរើនោះត្រូវបានទទួលជាប្រចាំខែ រហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សអប្បបរមាផ្ទាល់ខ្លួនរបស់យោធិនមានឋានន្តរសក្តិជាពលទោ ។

ខ- យោធិនពិការប្រភេទ "ខ" គ្រប់កំរិតថ្នាក់

១- យោធិនពិការប្រភេទ "ខ" ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពល ខេមរភូមិន្ទ នឹងបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពីប្រាំបី (៨) ខែ ដោយគិតរយៈពេល បំរើកងយោធពលខេមរភូមិន្ទ ដូចក្នុងចំណុច ក៣ ខាងលើ ។

២- យោធិនពិការត្រូវបានទទួលរបបឧបត្ថម្ភតាមកំរិតថ្នាក់ពិការជាប្រចាំ តាមកំរិតសមាមាត្រភាគរយនៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយ របស់យោធិនពិការ :

- កំរិតថ្នាក់ ១ បានទទួលទឹកប្រាក់សរុបស្មើនឹងកៅសិប (៩០) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- កំរិតថ្នាក់ ២ បានទទួលទឹកប្រាក់សរុបស្មើនឹងប៉ែតសិប (៨០) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- កំរិតថ្នាក់ ៣ បានទទួលទឹកប្រាក់សរុបស្មើនឹងចិតសិប (៧០) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬ ប្តី កូន ដូចយោធិនពិការប្រភេទ "ក" ។

គ- យោធិនពិការប្រភេទ "ក" និង "ខ" គ្រប់កំរិតថ្នាក់ ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែម :

១-នារាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យខួបរំលឹកគុណយោធិនពលី ពិការ (កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ) ត្រូវបានទទួលរបបឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ ។

២-ពេលមានជម្ងឺ របួស ឬពេលរបួសសើរី ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣-យោធិនពិការទាំងពីរភេទ ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និង ផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កអោយមាន មុខរបរសមស្របតាមសមត្ថភាព និង លទ្ធភាពជាក់ស្តែង ។

៤-ចំពោះយោធិននារីពិការ ត្រូវបានទទួលឧបត្ថម្ភជាបន្ថែមនូវការធានារ៉ាប់រងសង្គម ដូច ជាស្ត្រីដែលកំពុងបំរើការងាររាជការដែរ ។

៥-ចំពោះយោធិនពិការដែលនៅបំរើការងារ នៅពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ ត្រូវ ផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីដោះស្រាយប្រាក់ឧបត្ថម្ភជំនួយ មុខរបួស និងប្រាក់សោធននិវត្តន៍វិញ ។

**មាត្រា៧ថ្មី** : រាល់ការចំណាយលើរបបឧបត្ថម្ភ ដូចជាបានចែងក្នុងមាត្រា ៤ និង ៦ ត្រូវទទួល បន្ទុកដោយថវិការដ្ឋ ។ ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកដោះស្រាយដូចខាងក្រោម :

- ការចំណាយសម្រាប់បូជា ឬ បញ្ចុះសព ។
- ការចំណាយសម្រាប់ឧបត្ថម្ភជូនគ្រួសារយោធិនពលី មរណៈ បង្កស្លាប់ មួយលើកដំបូង ។
- ការចំណាយសម្រាប់ឧបត្ថម្ភបំប៉នសុខភាពយោធិនពិការ ។
- ការចំណាយសម្រាប់ឧបត្ថម្ភប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសម្រេច អោយចេញពីជួរកងយោធពលខេមរភូមិន្ទ ។
- ការចំណាយសម្រាប់ឧបត្ថម្ភជំនួយមុខរបួស របស់យោធិនពិការនៅបន្តការងារក្នុងកង- យោធពលខេមរភូមិន្ទ ។
- ការដោះស្រាយប្រាក់បៀវត្សសរុបបី (៣) ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេលរង់ចាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បំពេញសំណុំលិខិតបន្តដោះស្រាយប្រាក់ឧបត្ថម្ភ ។

ក្រៅពីរបបឧបត្ថម្ភដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយ គឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

**មាត្រា២** : អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការកែតំរូវលើអនុក្រឹត្យលេខ៤៦អនក្រ.បក និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជា និរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០០៥

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ទៀ បាញ់** **ញឹក ប៊ុនឆៃ**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ